អតីតយុទ្ធជន និងអភិបាលខេត្ត-ក្រុង ទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្ថ និងចុះហត្ថលេខានេះតទៅ ។

**មាត្រា ៤ -.**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវ ទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ហត្ថលេខា ព្រះហស្តលេខា

ទៀ បាញ់ ស៊ីសុវត្ថិ សិរីរ័ត្ន

***

## អនុក្រឹត្យ លេខ ៣៣ អនក្រ.បក

## ស្តីពី

## ការបង្កើតគណៈកម្មការជាតិ សំរបសំរួលសាកលវិទ្យាល័យ និងគ្រឹះស្ថានឧត្តមសិក្សានានា នៃព្រះរាជាណាចក្រកម្ពុជា

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-ឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥៩៩/៩៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភា

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

www.pheakdeylaw.com

## សំរេច

មាត្រា ១ .- បង្កើតគណៈកម្មការជាតិសំរាប់រៀបរៀងគោលនយោបាយ និងគ្រឹះស្ថានឧត្តមសិក្សានានា ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម សុខ អាន | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២-ឯកឧត្តម ម៉ុត ជន | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និង កីឡា | អនុប្រធាន |
| ៣-ឯកឧត្តម អ៊ឹម សិទ្ធី | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និង កីឡា | អនុប្រធាន |
| ៤-ឯកឧត្តម ស៊ន សំណាង | ប្រធានរាជបណ្ឌិត្យសភាកម្ពុជា | អនុប្រធាន |
| ៥-បណ្ឌិត ខៀវ ថាវិកា | ប្រធាននាយកដ្ឋានពត៌មាន និងសារគមនាគមន៍ | លេខាធិការ |
| ៦-ឯកឧត្តម ពិត ចំណាន | សាកលវិទ្យាធិការសាកលវិទ្យាល័យភ្នំពេញ | សមាជិក |
| ៧-ឯកឧត្តម ទូ គីមប៉ោរ | សាកលវិទ្យាធិការសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល | សមាជិក |
| ៨-ឯកឧត្តម នុយ គឿន | សាកលវិទ្យាធិការសាកលវិទ្យាល័យវិចិត្រសិល្បៈ | សមាជិក |
| ៩-ឯកឧត្តម ចាន់ ណារ៉េត | សាកលវិទ្យាធិការសាកលវិទ្យាល័យភូមិន្ទកសិកម្ម | សមាជិក |
| ១០-បណ្ឌិត ហ៊ាន សាហ៊ីប | ប្រធានវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១១-បណ្ឌិត ឆ សោ | ព្រឹទ្ធបុរសមហាវិទ្យាល័យគរុកោសល្យ | សមាជិក |
| ១២-លោក យក់ ឌុំយ | ព្រឹទ្ធបុរសរងមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច | សមាជិក |
| ១៣-លោក អ៊ុយ វ៉ាន់ថុន | ប្រធានក្រុមប្រឹក្សាភិបាលវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | សមាជិក |
| ១៤-ឯកឧត្តម អ៊ិច ថុន | ប្រធានវិទ្យាស្ថានជាតិគ្រប់គ្រង | សមាជិក |
| ១៥-ឯកឧត្តម លី គីមសុខ | នាយកសាលាភូមិន្ទរដ្ឋបាល | សមាជិក |
| ១៦-លោក មាស ពិនរិទ្ធ | ប្រធានគណៈគ្រប់គ្រងមហាវិទ្យាល័យឯកទេស | សមាជិក |

មាត្រា ២ .- គណៈកម្មការនេះមានភារកិច្ចសំរាប់រៀបចំ ធ្វើការកែទំរង់ និងពង្រឹងប្រព័ន្ធឧត្តមសិក្សានៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើអោយសំរេចគោលដៅជាយុទ្ធសាស្ត្រ ចំនួន ៦ ដូចខាងក្រោមនេះ :

១-ការពង្រឹងប្រព័ន្ធ និងរចនាសម្ព័ន្ធឧត្តមសិក្សាតាមរយៈបណ្តាញនានា ដែលឆ្លើយតបទៅនឹងតំរូវការចាំបាច់នាពេលបច្ចុប្បន្ន ។

២-ការប្រើប្រាស់អោយបានល្អប្រសើរជាអតិបរមានូវធនធានជាតិ និងអន្តរជាតិ ។

៣-ការពង្រឹងគុណភាពអប់រំ ដើម្បីផ្សារភ្ជាប់ឧត្តមសិក្សាទៅនឹងតំរូវការទីផ្សារពលកម្មអោយមានប្រសិទ្ធភាពខ្ពស់ ។

៤-ការរៀបចំកម្មវិធីឧត្តមសិក្សាអោយឆ្លើយតបនឹងតំរូវការចាំបាច់នៃការអភិវឌ្ឍន៍របស់ប្រទេស ។

៥-ការពង្រឹងភាសាជាតិ និងការទទួលស្គាល់តំលៃនៃភាសាបរទេសមួយចំនួនដែលរួមចំណែកដល់ការអភិវឌ្ឍន៍ ។

www.pheakdeylaw.com

ង-ការស្រាវជ្រាវពីគ្រប់គ្រងរុក្ខជាតិ និងស្ថាប័នឧត្តមគតិភាព ។

**មាត្រា៣** -.គណៈកម្មការនេះត្រូវបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលមានទីតាំងនៅរាជបណ្ឌិត្យសភាកម្ពុជា ដើម្បីចាត់ចែងការងារប្រចាំថ្ងៃ ។

**មាត្រា ៤** -. សមាជិកគណៈកម្មការទាំងអស់ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**មាត្រា ៥** -. គណៈកម្មការនេះមានសិទ្ធិប្រើត្រារបស់រាជបណ្ឌិត្យសភាកម្ពុជា ។

**មាត្រា ៦** -.បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧** :- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសុខាភិបាល សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលមានការពាក់ព័ន្ធ និងឯកឧត្តម អស់លោក ដែលមានរាយនាមខាងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យ លេខ ១៩៥ អនក្រ.តត

## ស្តីពី

## ការតម្លើងឋានន្តរស័ក្តិនាយទាហាន

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-ឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/២១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំង អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ

-យោងតាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

www.pheakdeylaw.com